# វ៉ាក់សាំងជំងឺ COVID-19 សម្រាប់យុវជន
## យល់ដឹងពីការផ្ដល់ការយល់ព្រម

Vaccinate WA
CovidVaccineWA.org

Washington State Department of Health (ក្រសួងសុខាភិបាលរដ្ឋវ៉ាស៊ីនតោន) ណែនាំឱ្យមនុស្សគ្រប់រូបដែលមានអាយុ 6 ខែឡើងចាក់វ៉ាក់សាំង។ ស្ថាប័នផ្ដល់វ៉ាក់សាំងជាច្រើនតម្រូវឱ្យមានការយល់ព្រមពីឪពុកម្ដាយ ឬអាណាព្យាបាលសម្រាប់មនុស្សអាយុក្រោម 18 ឆ្នាំដើម្បីចាក់វ៉ាក់សាំង។ ទោះយ៉ាងណា ប្រសិនបើអ្នកមានអាយុក្រោម 18 ឆ្នាំ និងរស់នៅដោយឯករាជ្យពីឪពុកម្ដាយ អ្នកអាចយល់ព្រមដោយខ្លួនឯងបានក្នុងករណីមួយចំនួន ឬទទួលបានការយល់ព្រមតាមរយៈសាលារៀនរបស់អ្នក ប្រសិនបើអ្នកមានបញ្ហាអស្ថិរភាពលំនៅដ្ឋាន និងមិនរស់នៅជាមួយឪពុកម្ដាយ ឬអាណាព្យាបាល។ ឯកសារនេះបង្ហាញពីប្រភេទខុសៗគ្នានៃការយល់ព្រមដែលត្រូវបានអនុញ្ញាតតាមច្បាប់រដ្ឋ របៀបស្វែងរកស្ថាប័នផ្ដល់វ៉ាក់សាំងដែលអាចផ្ដល់ជូនអ្នក និងរបៀបត្រៀមខ្លួនសម្រាប់ការណាត់ជួបចាក់វ៉ាក់សាំងរបស់អ្នក។

### មនុស្សពេញវ័យដែលអាចផ្ដល់ការយល់ព្រមសម្រាប់អ្នក៖



- ឪពុកម្ដាយ
- អាណាព្យាបាល ឬអ្នកចិញ្ចឹមស្របច្បាប់
- ឪពុកម្ដាយចិញ្ចឹម ឬបុគ្គលដទៃទៀតដែលទទួលបានសិទ្ធិអនុញ្ញាតពីតុលាការដើម្បីផ្ដល់ការយល់ព្រមចំពោះការថែទាំវេជ្ជសាស្ត្រសម្រាប់កុមារនៅកន្លែងថែទាំនៅក្រៅផ្ទះ (ជំពូកទី 13.32A ឬ 13.34 Revised Code of Washington (RCW, ច្បាប់រដ្ឋវ៉ាស៊ីនតោនដែលបានកែប្រែ))
- បុគ្គលដែលបានទទួលលិខិតអនុញ្ញាតដែលមានចុះហត្ថលេខា ដើម្បីធ្វើសេចក្ដីសម្រេចចិត្តលើការថែទាំសុខភាពសម្រាប់អ្នក
- សាច់ញាតិដែលទទួលខុសត្រូវលើការថែទាំសុខភាពអ្នក
- គិលានុបដ្ឋាកសាលារៀន អ្នកផ្ដល់ការប្រឹក្សា ឬអ្នកសម្របសម្រួលកិច្ចការជនគ្មានផ្ទះសម្បែង (ប្រសិនបើអ្នកត្រូវបានកំណត់ថាជាជនគ្មានផ្ទះសម្បែងតាមច្បាប់ McKinney-Vento Homeless Education Act របស់សហព័ន្ធ)*

### អ្នកអាចយល់ព្រមដោយខ្លួនឯងបានប្រសិនបើ៖



- **អ្នកមានការអនុគ្រោះតាមផ្លូវច្បាប់។** អ្នកមានអាយុ 16 ឆ្នាំឡើង ហើយអ្នកបានដាក់បញ្ជូនឯកសារ និងបានទទួលការអនុគ្រោះផ្លូវច្បាប់ពីឪពុកម្ដាយរបស់អ្នក។
- **អ្នកបានរៀបការជាមួយមនុស្សពេញវ័យ ឬអនីតិជនដែលបានទទួលការអនុគ្រោះផ្លូវច្បាប់។**
- **ស្ថាប័នផ្ដល់វ៉ាក់សាំងជាអ្នកកំណត់ថាតើអ្នកគឺជាអនីតិជនមានភាពចាស់ទុំឬអត់**តាម Mature Minor Doctrine (វិធានច្បាប់ស្តីពីភាពចាស់ទុំក្នុងការសម្រេចចិត្តរបស់អនីតិជន)។**

### *ព័ត៌មានបន្ថែមអំពីការយល់ព្រមដោយប្រើច្បាប់ McKinney-Vento៖

ស្របតាមច្បាប់រដ្ឋ គិលានុបដ្ឋាកនៅសាលារៀន អ្នកផ្ដល់ការប្រឹក្សានៅសាលារៀន និងអ្នកសម្របសម្រួលកិច្ចការសិស្សគ្មានផ្ទះសម្បែងមានសិទ្ធិផ្ដល់ការយល់ព្រមឱ្យចាក់វ៉ាក់សាំងដល់យុវជន ឬមនុស្សវ័យក្មេងគ្មានផ្ទះសម្បែង (ដូចបានកំណត់តាមច្បាប់ McKinney-Vento homeless education act របស់សហព័ន្ធ – មានជាភាសាអង់គ្លេសប៉ុណ្ណោះ) ដែលមិនស្ថិតក្រោមការមើលថែផ្នែករាងកាយដោយឪពុកម្ដាយ ឬអាណាព្យាបាល។

---

តំណភ្ជាប់ទៅកាន់ធនធាន៖ National Center for Homeless Education *ដែលជួយទ្រទ្រង់ការអប់រំសិស្សមិនស្ថិតក្រោមការមើលថែផ្នែករាងកាយដែលគ្មានផ្ទះសម្បែង* https://nche.ed.gov/wp-content/uploads/2018/10/youth.pdf - មានជាភាសាអង់គ្លេសប៉ុណ្ណោះ

### **ព័ត៌មានបន្ថែមអំពីវិធានច្បាប់ Mature Minor Doctrine៖

ស្ថាប័នផ្ដល់វ៉ាក់សាំងមួយចំនួនអនុញ្ញាតឱ្យអនីតិជនផ្ដល់ការយល់ព្រមដែលមានសុពលភាពតាមវិធានច្បាប់ "Mature Minor Doctrine" ប្រសិនបើពួកគេមានសមត្ថភាពយល់ដឹង ឬដឹងពីផលវិបាកនៃក្បួនវេជ្ជសាស្ត្រ។

ដើម្បីកំណត់ថាតើអ្នកជំងឺគឺជាអនីតិជនមានភាពចាស់ទុំឬអត់ ស្ថាប័នផ្ដល់វ៉ាក់សាំងនឹងវាយតម្លៃអនីតិជននោះទៅតាមអាយុ បញ្ញា ភាពចាស់ទុំ ការបណ្ដុះបណ្ដាល បទពិសោធន៍ ភាពខ្វះខាតឬមិនពឹងលុយកាក់ឪពុកម្ដាយ សកម្មភាពទូទៅក្នុងនាមជាមនុស្សពេញវ័យ និងសេរីភាពមិនស្ថិតក្រោមការគ្រប់គ្រងរបស់ឪពុកម្ដាយ។

**សម្រាប់ព័ត៌មានបន្ថែម៖** ចូលទៅកាន់ **COVIDVaccineWA.org ឬទូរសព្ទទៅលេខ 1-833-VAX-HELP** បន្ទាប់មកចុចសញ្ញា # សម្រាប់ជំនួយផ្នែកភាសា។

## ស្ថាប័នផ្តល់វ៉ាក់សាំងទទួលយកការយល់ព្រមតាមរបៀបពីរបីខុសៗគ្នា។

- ការយល់ព្រមផ្ទាល់មាត់ (តាមទូរសព្ទ ឬបង្ហាញវត្តមានផ្ទាល់)
- ការយល់ព្រមជាលាយលក្ខណ៍អក្សរ (ទម្រង់បែបបទ)
- ខ្លះតម្រូវឱ្យមានការយល់ព្រមទាំងផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរ។
- ការយល់ព្រមពីមនុស្សពេញវ័យសម្រាប់អ្នកដោយបង្ហាញវត្តមានផ្ទាល់។

## គន្លឹះដើម្បីទទួលបានការចាក់វ៉ាក់សាំង

- □ **ប្រើជម្រើសក្នុងតម្រងនៅលើ Vaccine Locator (កម្មវិធីស្វែងរកទីតាំងចាក់វ៉ាក់សាំង) (vaccinelocator.doh.wa.gov) ឬហៅទូរសព្ទទៅស្ថាប័នផ្តល់វ៉ាក់សាំង ដើម្បីដឹងពីប្រភេទនៃការយល់ព្រមដែលស្ថាប័នផ្តល់វ៉ាក់សាំងទទួលយក។** ជម្រើសក្នុងតម្រងដែលសមស្របសម្រាប់យុវជននៅលើកម្មវិធី Vaccine Locator នឹងជួយអ្នកក្នុងការស្វែងរកស្ថាប័នផ្តល់វ៉ាក់សាំងដែលនឹងធ្វើការលើស្ថានភាពរបស់អ្នក។ ឧទាហរណ៍ ប្រសិនបើអ្នកមានមនុស្សពេញវ័យដែលអាចផ្តល់ការយល់ព្រមសម្រាប់អ្នក ប៉ុន្តែមិនអាចទៅកន្លែងណាត់ជួបជាមួយអ្នកបានទេ សូមស្វែងរកស្ថាប័នផ្តល់វ៉ាក់សាំងដែលទទួលយកការយល់ព្រមជាលាយលក្ខណ៍អក្សរ។
- □ **ស្វែងរកទីតាំងចាក់វ៉ាក់សាំងដែលទទួលយកភ្លាមៗដោយគ្មានការណាត់ជួប ឬហៅទូរសព្ទដើម្បីណាត់ជួប** ប្រសិនបើអ្នកមិនមានឪពុកម្តាយ/អាណាព្យាបាលដែលអាចបំពេញទម្រង់បែបបទតាមអនឡាញបានទេ។ ស្ថាប័នផ្តល់វ៉ាក់សាំងជាច្រើនស្នើឱ្យឪពុកម្តាយ ឬអាណាព្យាបាលបំពេញទម្រង់បែបបទផ្តល់ការយល់ព្រម ដើម្បីធ្វើការណាត់ជួបតាមអនឡាញ។
- □ **ពិភាក្សាជាមួយសាលារៀនរបស់អ្នក។** ប្រសិនបើអ្នកកំពុងមានបញ្ហាអស្ថិរភាពលំនៅដ្ឋាន ច្បាប់ McKinney-Vento អាចអនុវត្តចំពោះអ្នកបាន។ (មើលផ្នែកខាងមុខសម្រាប់ព័ត៌មានបន្ថែម។) អ្នកអាចសហការជាមួយគិលានុបដ្ឋាកនៅសាលារៀន អ្នកផ្តល់ការប្រឹក្សានៅសាលារៀន ឬអ្នកសម្របសម្រួលកិច្ចការសិស្សគ្មានផ្ទះសម្បែងដើម្បីផ្តល់ការយល់ព្រម។
- □ **ត្រៀមសម្រាប់ប្រភេទនៃការយល់ព្រមដែលអ្នកត្រូវផ្តល់៖**
  - □ ប្រសិនបើមនុស្សពេញវ័យត្រូវមានវត្តមាននៅកន្លែងណាត់ជួបរបស់អ្នក សូមសម្របសម្រួលជាមួយមនុស្សពេញវ័យ។
  - □ ប្រសិនបើស្ថាប័នផ្តល់វ៉ាក់សាំងទទួលយកការយល់ព្រមជាលាយលក្ខណ៍អក្សរ សូមពិនិត្យមើលថាតើបុគ្គលដែលផ្តល់ការយល់ព្រមសម្រាប់អ្នកអាចបោះពុម្ព និងចុះហត្ថលេខាលើទម្រង់បែបបទបានឬអត់។
  - □ ប្រសិនបើអ្នកគឺជាអនីតិជនដែលបានទទួលការអនុគ្រោះផ្លូវច្បាប់ ឬជាអនីតិជនដែលបានរៀបការជាមួយអនីតិជនដែលបានទទួលការអនុគ្រោះផ្លូវច្បាប់ ឬជាមនុស្សពេញវ័យ អ្នកប្រហែលជាត្រូវយកឯកសារនោះមកជាមួយ។
  - □ ប្រសិនបើពួកគេកំពុងទទួលបានការយល់ព្រមដោយប្រើច្បាប់ McKinney-Vento ហើយបារម្ភថាស្ថាប័នផ្តល់វ៉ាក់សាំងនឹងមានសំណួរផ្សេងៗ អ្នកអាចយកច្បាប់ចម្លងនៃច្បាប់ស្តីពីការយល់ព្រមដោយទទួលបានព័ត៌មានគ្រប់គ្រាន់ទៅជាមួយ៖ RCW 7.70.065 – មានជាភាសាអង់គ្លេសប៉ុណ្ណោះ ហើយលើកឡើងពីផ្នែកសំខាន់ៗពាក់ព័ន្ធនឹងសាលារៀន។ (តំណភ្ជាប់ទៅកាន់ច្បាប់៖ https://app.leg.wa.gov/RCW/default.aspx?cite=7.70.065 – មានជាភាសាអង់គ្លេសប៉ុណ្ណោះ)។ សម្គាល់៖ នេះមិនមែនជាលក្ខខណ្ឌតម្រូវទេ។
  - □ ប្រសិនបើអ្នកកំពុងស្វែងរកការយល់ព្រមសម្រាប់ខ្លួនឯងតាមរយៈ Mature Minor Doctrine អ្នកប្រហែលជាត្រូវផ្តល់ឯកសារ និងព័ត៌មានដែលបង្ហាញថាអ្នករស់នៅដោយឯករាជ្យពីឪពុកម្តាយរបស់អ្នក។ ចំណុចនេះមិនតម្រូវដោយស្ថាប័នផ្តល់វ៉ាក់សាំងទាំងអស់ទេ ប៉ុន្តែប្រហែលជាអាចជួយបាន។ ស្ថាប័នផ្តល់វ៉ាក់សាំងមួយចំនួនមិនធ្វើការវាយតម្លៃអនីតិជនមានភាពចាស់ទុំនៅនឹងកន្លែងទេ ប៉ុន្តែទទួលយកការវាយតម្លៃអនីតិជនមានភាពចាស់ទុំពីស្ថាប័នផ្តល់វ៉ាក់សាំងមុនៗ។